**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

**Nation Religion King**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**

**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**

**Criminal Case File /Dossier pénal**

**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ**/Investigation/Instruction

**លេខ**/No: 002/19-09-2007-ECCC/OCIJ

# សេចក្តីសម្រេចឃាត់ខ្លួន

Décision de placement en Garde á Vue

Police Custody Decision

យើង, **យូ ប៊ុនឡេង** និង **Marcel Lemonde**, សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ២ ២១ ៤៥ ៥១ ៥៧ និង ៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ

**អៀង សារី** ភេទ ប្រុស កើតនៅឆ្នាំ ១៩២៥ នៅភូមិ លឿង វ៉ា ឃុំ លឿង វ៉ា ស្រុក ត្រាវិញ ខេត្តត្រាវិញ (កម្ពុជាក្រោម)

ប្រពន្ធឈ្មោះ **អៀង ធីរិត** (រស់) មានកូន ០៤ នាក់ ឪពុកឈ្មោះ **គឹម រៀម** (ស្លាប់) ម្តាយឈ្មោះ **ត្រាន់ ធិឡឺយ** (ស្លាប់) មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៤៧ B ផ្លូវលេខ ២១ ក្រុម ៣៦ មណ្ឌល ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុងភ្នំពេញ។

យល់ឃើញថា ឈ្មោះ **អៀង សារី** ត្រូវបានដាក់អោយស្ថិតនៅក្រោមការពិនិត្យថ្ងៃនេះ ហើយមេធាវីរបស់ជននេះស្នើសុំអោយលើកពេលកិច្ចពិភាក្សាដេញដោលមុនពេលសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីអាចមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី

យល់ឃើញថាការស្នើសុំនេះមានលក្ខណៈស្របច្បាប់ស្របតាមវិធាន ៦៣-១ នៃវិធានផ្ទៃក្នុងដែលចែងថា " *ជនត្រូវចោទត្រូវមានរយៈពេលគ្រប់គ្រាន់ដើម្បីការពារខ្លួន* " ប៉ុន្តែវិធានផ្ទៃក្នុងមិនបានចែងអំពីការលើកពេលកិច្ចពិភាក្សាដេញដោលនេះឡើយ

យល់ឃើញថាអនុលោមតាមវិធាន ២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើក្នុងពេលដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញ មានបញ្ហាចោទឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុង សហចៅក្រមស៊ើបសួរអាចសម្រេចសេចក្តី "*ដោយយោងជាពិសេសដល់គោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និង នីតិវិធីព្រហ្មទណ្ឌជាធរមាន។ នៅក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងត្រូវដាក់ជូនគណៈកម្មាធិការវិធាន និង នីតិវិធីក្នុងរយៈពេលឆាប់រហ័សដែលអាចធ្វើទៅបាន*" ។

យល់ឃើញថាសំណើសុំធ្វើវិសោធនកម្មទើបតែត្រូវបានដាក់ជូនគណៈកម្មាធិការវិធាន និង នីតិវិធី ដើម្បីអាចអោយរៀបចំការលើកពេលកិច្ចពិភាក្សាដេញដោល ហើយកំពុងរង់ចាំសេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គ និង យល់ឃើញថាដើម្បីគោរពសិទ្ធិការពារក្តី ជាការចាំបាច់ដែលត្រូវអនុវត្តវិធាន ២ ដោយយកមកអនុវត្ត ដូចគ្នានូវបញ្ញត្តិនៃវិធាន ៤៥ (៤) នៃវិធានផ្ទៃក្នុង និង សម្រេចឃាត់ខ្លួនលោក **អៀង សារី** សម្រាប់រយៈពេល ៤៨ ម៉ោង។

## ហេតុដូច្នេះ សម្រេច

- បង្គាប់ឃាត់ខ្លួនជាបន្ទាន់ឈ្មោះ **អៀង សារី** នៅមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងថេរៈវេលា អតិបរិមា ៤៨ ម៉ោង (សែសិបប្រាំបី) ដោយគិតចាប់ពីពេលជូនដំណឹងអំពីដីកានាំខ្លួន និងក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងបទបញ្ញត្តិនៃវិធាន ៥១ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- ប្រកាសថាការចូលខ្លួនជាលើកដំបូងនឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដោយយោងតាមវិធាន ៥៧ និង ៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ធ្វើនៅភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១៥ និង ៣០ នាទី

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-Juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង